ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ០០៤ កសក

រាជធានីភ្នំពេញ, ថ្ងៃទី.០២...ខែ.មករា..ឆ្នាំ ២០១៤

សូមគោរពជូន

-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

-ឯកឧត្តមប្រធានគណៈកម្មការផែនការ សេដ្ឋកិច្ច វិនិយោគ កសិកម្ម បរិស្ថាន និងអភិវឌ្ឍន៍ជនបទនៃព្រឹទ្ធសភា

-ឯកឧត្តមប្រធានគណៈកម្មការផែនការ សេដ្ឋកិច្ច វិនិយោគ កសិកម្ម បរិស្ថាន និងអភិវឌ្ឍន៍ជនបទនៃរដ្ឋសភា

-ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

-ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅអមក្រសួងព្រះបរមរាជវាំង

-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា

-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា

-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ឯកឧត្តមនាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់

**កម្មវត្ថុ** : របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣** ។

ន័យដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមផ្ញើជូនឯកឧត្តម នូវរបាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣** ចំនួន០១ច្បាប់ ដើម្បីជូនជ្រាបជាសេចក្តីរាយការណ៍ ។

សូមឯកឧត្តម ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ចម្លងជូន**

-គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង

-ឯកសារ កាលប្បវត្តិ

បណ្ឌិត អ៊ុក រ៉ាប៊ុន

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# (ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៣)

## I- សភាពការណ៍រួម

ក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ ស្ថានភាពអាកាសធាតុទទួលរងឥទ្ធិពលពីជ្រលងសម្ពាធខ្ពស់ស៊ីបេរីនិងមូសុងឦសាន ធ្វើឲ្យសីតុណ្ហភាពធ្លាក់ចុះ ផ្ទៃមេឃមានពពកពីតិចទៅមធ្យមនិងមានភ្លៀងធ្លាក់តិចតួចនៅតាមតំបន់មួយចំនួននៃរាជធានីខេត្ត។ ជាមួយនោះ ប្រជាកសិករបានខិតខំជំរុញការងារប្រមូលផលដំណាំ ជាពិសេសដំណាំស្រូវរដូវវស្សានាពេលនេះប្រមូលផលបាន ៣៣,៦១% នៃផ្ទៃដីអនុវត្ត។ ទន្ទឹមនឹងនោះ ប្រជាកសិករបាននឹងកំពុងជំរុញដំណើរការការងារបង្កបង្កើនផលរដូវប្រាំងឆ្នាំ២០១៣-២០១៤ ក្នុងនោះដំណាំស្រូវសម្រេចបាន ២៧,២៥ភាគរយ នៃផែនការដាំដុះ។

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ដំណាំស្រូវរដូវវស្សាឆ្នាំ២០១៣

#### ១.១.១ ដំណាំស្រូវ

-ផ្ទៃដីភ្ជួររាស់សរុបចំនួន១៩.៣០៣ហិកតា លើសឆ្នាំមុនចំនួន១៨.៦៥១ហិកតា

-ផ្ទៃដីសាបសរុបចំនួន២.៣៨៣ហិកតា តិចជាងឆ្នាំមុនចំនួន៦៣៦ហិកតា

-ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន១០៣.២៩១ហិកតា ស្មើនឹង២៧,២៥ភាគរយ នៃផែនការ៣៧៨.៩៩០ហិកតា តិចជាងឆ្នាំមុនចំនួន៣២.៧២៤ហិកតា

-ការងារប្រមូលផលស្រូវរដូវវស្សាសម្រេចបានលើផ្ទៃដីចំនួន៨៦១.២៤៨ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន២.៤៨៤.៥៨៣តោន និងទិន្នផលជាមធ្យមចំនួន២,៨៨៥តោនក្នុងមួយហិកតា។

*- ផ្ទៃដីប៉ះពាល់និងខូចខាតដោយកង្វះទឹក ÷*

- សំណាបសរុបចំនួន ៦៣១ហិកតា ក្នុងនោះខូចខាតចំនួន ២៥០ហិកតា
- សន្ទូង-ពង្រោះសរុបចំនួន ៩.៩៩៧ហិកតា។

*- ផ្ទៃដីប៉ះពាល់និងខូចខាតដោយទឹកជំនន់ ÷*

- សំណាបចំនួន ១២០ហិកតា ក្នុងនោះខូចខាតចំនួន ៨២ហិកតា
- សន្ទូង-ពង្រោះសរុបចំនួន ៣៧៨.៥៧២ហិកតា ក្នុងនោះខូចខាតចំនួន ១២៨.៤២១ហិកតា។

*- លទ្ធភាពស្តារនិងផ្ទៃដីស្តារបានជាក់ស្តែងលើសន្ទូង-ពង្រោះ ÷*

- ផ្ទៃដីលទ្ធភាពស្តារចំនួន ៥៧.៩៨២ហិកតា
- ផ្ទៃដីស្តារបានជាក់ស្តែងចំនួន ៣៣.៩៧៦ហិកតា។


អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

១.១.២ ដំណាំរួមផ្សំ

ផ្ទៃដីសម្រេចបានចំនួន៨.៤៨៧ហិកតា ស្មើនឹង១៩,៣១ភាគរយ នៃផែនការសរុប៤៣.៩៤៤ហិកតា តិចជាងឆ្នាំមុន៨.២២០ហិកតា ក្នុងនោះមាន÷

-ផ្ទៃដីដាំពោតចំនួន៣.៩៩៧ហិកតា តិចជាងឆ្នាំមុន១.៥៣៨ហិកតា ក្នុងនោះផ្ទៃដីដាំពោតក្រហមមាន ២.៩០២ហិកតា

-ផ្ទៃដីដំឡូងឈើចំនួន៨២ហិកតា តិចជាងឆ្នាំមុន២.១២១ហិកតា

-ផ្ទៃដីដំឡូងជ្វាចំនួន៣៣៨ហិកតា តិចជាងឆ្នាំមុន៧៩២ហិកតា

-ផ្ទៃដីបន្លែគ្រប់មុខចំនួន២.៤៣២ហិកតា តិចជាងឆ្នាំមុន២.៦៩៧ហិកតា

-ផ្ទៃដីសណ្តែកបាយចំនួន១.៦៣៨ហិកតា តិចជាងឆ្នាំមុន១.០៧២ហិកតា ។

១.១.៣ ដំណាំឧស្សាហកម្ម

ផ្ទៃដីសម្រេចបាន២.៦៨៦ហិកតា ស្មើនឹង១៣,៤០ភាគរយ នៃផែនការសរុប ២០.០៤៤ហិកតា លើសឆ្នាំមុន ១.០៣៥ហិកតា ក្នុងនោះមាន÷

-ផ្ទៃដីសណ្តែកដីចំនួន ៧០៩ហិកតា លើសឆ្នាំមុន ១៦៣ហិកតា

-ផ្ទៃដីល្ងចំនួន ៦ហិកតា តិចជាងឆ្នាំមុន ៧ហិកតា

-ផ្ទៃដីអំពៅចំនួន ២២០ហិកតា លើសឆ្នាំមុន ១៣១ហិកតា

-ផ្ទៃដីថ្នាំជក់ចំនួន ១.៧៥១ហិកតា លើសឆ្នាំមុន ៧៤៨ហិកតា។

## ២ ផ្នែកព្រៃឈើ

### ២.១ ការងារចំណូលព្រៃឈើ

-ចំណូលពីផលព្រៃឈើចូលថវិកាជាតិសរុបចំនួន៥០.៩៤៨.៧២១.១៨៣រៀល។

### ២.២ ការងារព្រៃឈើនិងសហគមន៍ព្រៃឈើ

-ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP)ចេញពីព្រៃគុបផ្តល់ផលក្រៅពីព្រៃសម្បទាន÷ ឈើហ៊ុបមូលសរុបចំនួន៩.៣៩៧ម³ ឈើអារចំនួន៦៣៩ម³ ឈើជ្រុងចំនួន១.៦២០ម³ កូនឈើចំនួន២៥.៣៧៣ដើម អុសចំនួន ១០.៥៧១ស្ទែរ និងជ័រទឹកចំនួន៦៩តោន។

### ២.៣ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

-ជំរឿនសត្វស្លាបដែលមាននៅក្នុងតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(អាងត្រពាំងថ្ម បឹងព្រែកល្ពៅ កំពង់ធំ-សៀមរាប និងអន្លង់ព្រីង) ដែលមានសត្វស្លាបចំនួន១៨៩ប្រភេទ ស្មើនឹង២៦.៤២៩ក្បាល

-ផ្តល់ចំណីដល់សត្វត្មាតចំនួន០២លើក នៅតំបន់វាលបឹងទាល់នៃព្រៃការពារព្រះវិហារ និងនៅតំបន់ព្រៃការពារមណ្ឌលគីរី ដោយមានសត្វត្មាតសរុបចំនួន៣៤ក្បាល

-ការពារសម្បុកសត្វត្រដក់តូចចំនួន៧៩ និងត្រយ៉ងចង្កំកសចំនួន០៥ នៅតំបន់ព្រៃការពារព្រះវិហារ ព្រៃការពារមណ្ឌលគីរី និងតំបន់ទន្លេមេគង្គលើ

-ប្រមូលយកកូនក្រពើទើបញាស់ចំនួន៣៣ក្បាលពីស្ទឹងអារ៉ែង ឃុំជីនាប់ ស្រុកថ្មបាំង ខេត្តកោះកុង មកថែបំប៉ននៅស្នាក់ការល្បាតអារ៉ែងរបស់រដ្ឋបាលព្រៃឈើក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង រង់ចាំការដោះលែងចូលបឹងធម្មជាតិ

-ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាសរុបចាប់ពីដើមឆ្នាំ សត្វចំណូលថ្មីចំនួន៧៤១ក្បាល សត្វកើតថ្មីចំនួន៦១ក្បាល សត្វដោះលែងចំនួន៤៧៥ក្បាល សត្វស្លាប់ចំនួន១៤១ក្បាល ព្យាបាលសត្វចំនួន២៥៤ក្បាល យកសំណាកទៅពិសោធន៍ចំនួន២៧៦ក្បាល ធ្វើឱ្យសន្លប់ចំនួន១៧២ក្បាល ទម្លាក់សត្វល្អិតចំនួន៦១៩ក្បាល វះកាត់សាកសពសត្វចំនួន៤៧ក្បាល ដាក់លេខកូដចំនួន២១ក្បាល ចាក់វ៉ាក់សាំងចំនួន៧៨៦ក្បាល សាងសង់របងហ៊ុមព័ទ្ធនិងទ្រុងសត្វថ្មីលើដីចំនួន១៣.៨៨៨ម² សាងសង់ទ្រុងសត្វនិងអគារផ្សេងៗចំនួន៣.៦៤៧ម² ជួសជុល

ផ្លូវចំនួន៣៦៥.៣៨៣ម៉ែ សាងសង់សំណង់ផ្សេងៗចំនួន១.១២៣ម៉ែ និងភ្លឺអនាម័យព្រៃ២០៩.៥៣៤ម៉ែ ដាំកូនឈើចំនួន ១.៥០៤ដើម បណ្តុះផ្កាលម្អ(ផ្កាក្រដាស)ចំនួន៥.១២៣ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន១១.១៤០នាក់

-ក្រុមហ៊ុនចំនួន ០៧ កំពុងចិញ្ចឹមសត្វក្តាមចំនួន៧៥.៦១១ក្បាល។

## ២.៤ ការងារដាំដើមឈើ

-ស្រាវជ្រាវពូជឈើដូនចែមនៅចម្ការពូជឈើក្នុងព្រៃធម្មជាតិលើផ្ទៃដីសរុបចំនួន៣៥០ហិកតាស្ថិតនៅស្រុកសណ្តាន់ ខេត្តកំពង់ធំ និងចម្ការពូជឈើទាលទឹក នៅស្ថានីយក្បាលឆាយទំហំ៥ហិកតា និងដាំកូនឈើបានចំនួន៨.៣០០ដើម ដើម្បីអភិវឌ្ឍធនធានសេនេទិចព្រៃឈើ

-ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើចំនួន០៥របស់រដ្ឋបាលព្រៃឈើ ដាំកូនក្រញូងបានចំនួន១០ហិកតា និងស្ថានីយដាំឈើចំនួន១០ លើផ្ទៃដីចម្ការឈើដាំទំហំចំនួន៣.៨៦៨ហិកតា ត្រូវធ្វើការថែទាំនិងការពារជាប្រចាំ។ ដោយឡែកចម្ការឆ្នាំទី១ ឬឆ្នាំទី២ ដែលទទួលរងការខូចខាតដោយភ្លើងឆេះកំពុងរៀបចំដាំបំពេញផែនការឡើងវិញនៅតាមស្ថានីយដាំឈើមានក ភ្នំត្បូលេន ក្បាលឆាយ និងក្រសាំង

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចបានឈូសឆាយដីព្រៃចំនួន៤.៥៩៦,៣៣ហិកតា និងដាំកូនឈើនិងកូនកៅស៊ូចំនួន ៥.៥៥៥,៥៥ហិកតា

-ថ្នាលបណ្តុះកូនឈើរបស់រដ្ឋបាលព្រៃឈើអនុវត្ត÷ កូនឈើសល់ស្តុកក្នុងឆ្នាំ២០១២ចំនួន៧៩៨.០៤២ដើម កូនឈើបណ្តុះបានចំនួន៨៧៨.៥០១ដើម និងចែកចាយកូនឈើបានចំនួន៨១៣.៦៦៩ដើម

-ដំណាំកសិរុក្ខកម្ម មានឡូត៍ស្រាវជ្រាវប្រព័ន្ធកសិរុក្ខកម្មទំហំ៥ហិកតា ដែលមានទីតាំងនៅខេត្តកំពង់ធំ បានបញ្ចប់ការងារដាំដុះដំណាំកសិរុក្ខកម្មតាមផែនការ។

## ២.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

### ២.៥.១ ការងារពាណិជ្ជកម្មនាំចេញ នាំចូល

-ពិនិត្យឯកសារស្នើសុំពាក់ព័ន្ធនឹងការនាំចេញនាំចូលចំនួន០៣ក្រុមហ៊ុន

-ផ្តល់អាជ្ញាប័ណ្ណនាំចេញឈើគ្រប់ប្រភេទជូនក្រុមហ៊ុនចំនួន០២ ដែលមានបរិមាណឈើចំនួន៦.២៥២,១៨២ម៉ែ។

### ២.៥.២ ការងារឧស្សាហកម្ម

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញជូនក្រុមហ៊ុនចំនួន០១ ស្មើនឹង១៨សន្លឹក ដែលមានបរិមាណឈើចំនួន២.០៩៨,៨៤៤ម៉ែ។

## ២.៦ ការងារនីតិកម្មនិងវិវាទ

-បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃសរុបចំនួន១៦៣ករណី

-ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើហ៊ុបមូលចម្រុះប្រភេទចំនួន២៤១,៨៤៤ម៉ែ ឈើអារចំនួន១៨៦,៧៩៦ម៉ែ ឈើក្រាក់ត្រញូងចំនួន៥១,២៤៥ម៉ែនិង១.០៥៩គ.ក្រ ឈើជន្លង់ម្រេចចំនួន២៦៤ដើម សសរមូលចំនួន៣៣ដើម អុសចំនួន២៤ស្ទេរ គល់ឈើ(ផ្ចង់)ចំនួន០១គល់ ពកឈើចំនួន២២៥គ.ក្រ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន ២៩,៤០គ.ក្រនិង៧៩ក្បាល ស្បែកពស់ថ្លាន់ចំនួន១១បន្ទះ រថយន្តចំនួន៧៤គ្រឿង ម៉ូតូចំនួន១១គ្រឿង ទូក-កាណូតចំនួន០៦គ្រឿង ម៉ាស៊ីនផ្សេងៗចំនួន១០គ្រឿង និងសម្ភារផ្សេងៗទៀត ព្រមទាំងដកហូតដីព្រៃឈើចំនួន២៦២,៦៥០ហិកតា។

# ៣ ផ្នែកជលផល

## ៣.១ អាជីវកម្មនេសាទ

### ៣.១.១ នេសាទទឹកសាប

-ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៣-២០១៤ *ក្នុងខែចំនួន២.០០០តោន* សរុបបានចំនួន៣.៥០០តោន ស្មើ៣៥% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២.០០០តោន

-នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៣ *ក្នុងខែចំនួន២៥.០០០តោន* សរុបបានចំនួន២៣០.០០០តោន ស្មើ ៧៦,៦៧% នៃផែនការ៣០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២០.០០០តោន

-នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៣ *ក្នុងខែចំនួន១៥.០០០តោន* សរុបបានចំនួន១១០.០០០តោន ស្មើ ៧៣,៣៣% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២០.០០០តោន ។

៣.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៣

*-ក្នុងខែចំនួន៧.០០០តោន* សរុបបានចំនួន៩០.០០០តោន ស្មើ១០០%នៃផែនការ៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៤.០០០តោន។

**៣.២ វារីវប្បកម្ម**

-ការចិញ្ចឹមត្រីនិងបង្គា *ក្នុងខែចំនួន៤.០០០តោន* សរុបបានចំនួន៧៥.០០០តោន ស្មើ៩៣,៧៥%នៃផែនការ ៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣.០០០តោន

-ការចិញ្ចឹមក្រពើ *ក្នុងខែចំនួន៣៥.០០០ក្បាល* សរុបបានចំនួន២៣៥.០០០ក្បាល ស្មើ១១៧,៥០% នៃផែនការ ២០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥.០០០ក្បាល

-ការភ្ញាស់កូនត្រីពូជ *ក្នុងខែចំនួន១០.០០០.០០០កូន* សរុបបានចំនួន១៣០.០០០.០០០កូន ស្មើ៨៦,៦៧% នៃផែនការ១៥០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥.០០០.០០០កូន ។

**៣.៣ ការកែច្នៃផលនេសាទ**

-ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១២-២០១៣ *ក្នុងខែចំនួន៥.០០០តោន* សរុបបានចំនួន៦០.០០០តោន ស្មើ៦០% នៃផែនការ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២៣.០០០តោន

-ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៣ *ក្នុងខែចំនួន៥០០តោន* សរុបបានចំនួន៧.០០០តោន ស្មើ១០៨,៣៣% នៃផែនការ៦.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៤០០តោន

-ការផលិតទឹកត្រី *ក្នុងខែចំនួន២.០០០.០០០លីត្រ* សរុបបានចំនួន៥០.០០០.០០០លីត្រ ស្មើ៨៣,៣៣% នៃផែនការ៦០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២.០០០.០០០លីត្រ។

**៣.៤ ការនាំចេញផលនេសាទ**

-ផលនេសាទស្រស់ *ក្នុងខែចំនួន១.០០០តោន* សរុបបានចំនួន១០.៥០០តោន ស្មើ៥២,៥០% នៃផែនការ២០.០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២.០០០តោន

-ផលនេសាទកែច្នៃ *ក្នុងខែចំនួន២០០តោន* សរុបបានចំនួន៥.២០០តោន ស្មើ៦០% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣០០តោន។

**៣.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស**

-កំណត់ហេតុបទល្មើសក្នុងខែចំនួន៣៣៦ករណី ក្នុងនោះបញ្ជូនទៅតុលាការចំនួន០៣ករណី ជនសង្ស័យចំនួន ០៣នាក់ ជាប់ពន្ធនាគារចំនួន០៣នាក់

-ធ្វើការរុះរើបំផ្លាញចោលនិងដកហូតវត្ថុតាងរួមមាន÷ របាំងស្បៃមុងនិងសាច់អួនប្រវែង១១៧.៨២៦ម៉ែត្រ របាំងព្រួលប្រវែង៩២ម៉ែត្រ មងប្រវែង៧.៣៩០ម៉ែត្រ ឈ្នក់/ឆ្នុកចំនួន៨២គ្រឿង បរ លូស្បៃមុងនិងសាច់អួនចំនួន១.៧០៧មាត់ ឧបករណ៍ឆក់ត្រីចំនួន៣២គ្រឿង លប/តុម/ឡើ/បួមចំនួន២៥៩គ្រឿង ដាយត្រីចំនួន៣២មាត់ បង្គោលចំនួន៥១.៥១៩ដើម កាណូតចំនួន០៤គ្រឿង ទូកចំនួន០១គ្រឿង លែងកូនត្រីឆ្តោនិងត្រីរស់ចំនួន១០.០០០ក្បាល និងលែងត្រីចម្រុះចូលដែនទឹកធម្មជាតិវិញចំនួន១០.៥៩២គ.ក្រ

-ធ្វើការប្រជុំផ្សព្វផ្សាយនៅតាមមូលដ្ឋានចំនួន០៩ដង ដែលមានអ្នកចូលរួមចំនួន៩៦៧នាក់។ ជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

**៣.៦ ការប្រមូលថវិកា**

-ចំណូលពីវិស័យជលផល *ក្នុងខែចំនួន៧៣៥.៥៧៣.១២៥រៀល* សរុបបានចំនួន២.៧៤៦.៥៧៩.៥១៦រៀល ស្មើ៩៣,២០% នៃផែនការ២.៩៤៧.០០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន១.៣២៣.៥៣៩.២៨៤រៀល។

## ៤ ផ្នែកផលិតកម្មនិងបសុពេទ្យ

### ៤.១ ការងារស្ថានីយ៍ពិសោធន៍ពូជជ្រូក-គោ

-ជ្រូកសរុបចំនួន២៧០ក្បាល ក្នុងនោះជ្រូកបាចំនួន១២ក្បាល ជ្រូកមេចំនួន១៤៦ក្បាល និងកូនជ្រូកចំនួន១១២ក្បាល

-គោសរុបចំនួន២០៥ក្បាល ក្នុងនោះគោឈ្មោលចំនួន៥៤ក្បាល គោញីចំនួន១៥១ក្បាល គោកើតថ្មីចំនួន៥ក្បាល និងគោងាប់ចំនួន១ក្បាល។

### ៤.២ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុពេទ្យ

-ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក

-រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

-អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅរាជធានី ខេត្ត

-ផ្នែកពិនិត្យវត្ថុវិភាគសរុបចំនួន ៦៩សំណាក

-ផ្នែកសរីរវោគសាស្ត្រសរុបចំនួន ២៣ក្បាល ។

### ៤.៣ ការអនុវត្តវិធានបសុពេទ្យ

-ទទួលទូរស័ព្ទហៅចូលសរុបចំនួន ១០ករណី មកពីតាមបណ្តារាជធានី ខេត្ត សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព និងរាយការណ៍ពីបក្សីឈឺ ងាប់

-ធ្វើការឃាត់ចាប់បទល្មើសចលនាដឹកជញ្ជូនមាន់សាច់រស់ខុសច្បាប់បានចំនួន២ករណី សរុបចំនួន២.៩៤០ក្បាល និងផាកពិន័យជាទឹកប្រាក់ចំនួន៥លានរៀល

-ធ្វើការត្រួតពិនិត្យការដឹកជញ្ជូនគោ-ក្របីចំនួន៦ករណី ជ្រូកចំនួន៨ករណី និងស៊ុតចំនួន១ករណី

-ចុះធ្វើការរឹបអូសទាំងស្រុងនិងជាចំណែកសាច់សរុបចំនួន៥០គ.ក្រ និងត្រួតពិនិត្យបរិមាណសាច់និងផលិតផលមិនស្អាតចំនួន៨គ.ក្រ

-ចុះធ្វើការរឹបអូសផលិតផលខូចគុណភាពបំផ្លាញចោលគ្រឿងក្នុងជ្រូក(សួត ថ្លើម ផាល និងតម្រង់នោម)ចំនួន ៨,៦គ.ក្រ និងថ្លាំងសាច់ជ្រូកចំនួន២៦,៥គ.ក្រ និងបំផ្លាញចោលតាមវិធានបសុពេទ្យ

-ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅសត្តឃាតដ្ឋានចំនួន៣៤លើក កសិដ្ឋានចិញ្ចឹមមាន់ចំនួន៨៥លើក កសិដ្ឋានចិញ្ចឹមជ្រូកចំនួន៤៧លើក កសិដ្ឋានចិញ្ចឹមទាចំនួន១២លើក កន្លែងពិឃាតមាន់ចំនួន១លើក ទ្រុងចិញ្ចឹមសត្វចំនួន៦លើក បរិវេណភូមិចំនួន១៨លើក កន្លែងទិញលក់ប្រមូលផ្តុំនិងពិឃាតបក្សីចំនួន២លើក លើមធ្យោបាយដឹកជញ្ជូនចំនួន៦៣លើក និងកន្លែងស្តុកសត្វរបស់ក្រុមហ៊ុនចំនួន១៣លើក

-ធ្វើការទប់ស្កាត់ចលនាបក្សីនិងផលិតផលបក្សីដែលនាំចូលពីប្រទេសជិតខាង ដោយបានណែនាំប្រជាពលរដ្ឋ និងអាជីវករឲ្យយល់ដឹងពីផលវិបាកដែលបណ្តាលមកពីជំងឺផ្តាសាយបក្សី ។

### ៤.៤ ការងារឡជីវឧស្ម័ន

-ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន

-ផលិតឡជីវឧស្ម័នសរុបចំនួន ៨៤ឡ ។

## ៥ ផ្នែកកៅស៊ូ

### ៥.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០២-២០១១ (ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ (តោន) |
|---|---|---|---|---|---|
| *I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ* | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៣៦៧,៧០ | ៣៧០,៧១ | ៣០៨,៨៧ | ២៩៤,០០ |

| | | | | | |
|---|---|---|---|---|---|
| *សរុប I* | | *៣៦៧,៧០* | *៣៧០,៧១* | *៣០៨,៨៧* | *២៩៤,០០* |
| *II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន* | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិទីកា អ៊ិនវេសមេន គ្រុប | ៩.៣៥៦,៨៨ | ៦.៦៨៩,៤៤ | ១៤.៣០០,៧៧ | ១១.៦៧៨,៦៨ |
| ២ | ក្រុមហ៊ុន ស៊ីហ្វាប់ឃើលីមីធីត (រតនគិរី) | ៨៦៧,៩៤ | ១.៦២៥,៩០ | ៨៤២,៧២ | ៥៤០,០០ |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៦៦,៨០ | ៨៨៥,០១ | ៩២៩,១៩ | ៨៩៦,៤០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.០៥៦,៣២ | ៣.២៦៦,៩២ | ៣.៤៣១,២០ | ៣.២៤១,០០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៩៥,៥៨ | ៥.២៥៩,០៨ | ៣.៣៧៧,២៤ | ២.៦៤២,៧២ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វ៊ីសេសស័ (ស្នួល) | ១.៥៦១,៨០ | ២.៨២៤,៩១ | ២.២២៦,២១ | ២.១៤៤,៥០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.១៧៧,០៤ | ១.១៥៩,០០ | ៩៧៤,៥០ | ៧៦៤,០០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ២.១៣៥,២៩ | ៣.៦៨៧,៥៣ | ១.០៨៥,៦៣ | ៧៩៩,០០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | | ១.៥៧០,៦៣ | | |
| ១០ | ក្រុមហ៊ុនក្រេក (ខេមបូឌា) ខូអិលធីឌី | ២.៨៥២,៧២ | ២.៦១៨,៧៥ | ១.៩៥១,៣១ | ១.១៩៤,០០ |
| *សរុប II* | | *២៥.៥៧០,៣៧* | *២៥.៥៨៦,៦៧* | *២៩.១១៨,៧៧* | *២៣.៩០០,៣០* |
| *III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច* | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | ១៣៥.៤៤៦,០០ | | |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៥២.៥០៥,០០ | ៨២.០៥៦,០០ | ៤៧.៤១២,០០ | ៤៦.៥០០,៥០ |
| *សរុប III* | | *៥២.៥០៥,០០* | *២១៧.៥០២,០០* | *៤៧.៤១២,០០* | *៤៦.៥០០,៥០* |
| សរុប I+II+III | | ៧៨.៤៤៣,០៧ | ២៤៧.៤២៩,៣៨ | ៧៦.៨៣៩,៦៤ | ៧០.៦៩៤,៨០ |

### ៥.២ ការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

-ដឹកនាំការសរសេរសារណាបទរបស់និស្សិតសាលាជាតិកសិកម្មកំពង់ចាមចំនួន០៣នាក់។

### ៥.៣ ការស្រាវជ្រាវអំពីការបង្កាត់ពូជ

-ចុះយកសំណាកស្លឹកកៅស៊ូដើម្បីវិភាគ DNA នៅស្រុកតំបែរ និងចម្ការកៅស៊ូជុបបានចំនួន៥២៧សំណាក លើក្លូនចំនួន២៤គឺ GT1, PR261, RRIV2, RRIV4, PB260, PR255, PB311, IRCA230, KV4, BPM24, PR107, PR306, RRIC110, PB347, PB324, RRIM600, PR300, RRIM712, RRIC121, PR303, IRCA130, RRIM2014, RRIM2025។

### ៥.៤ ការស្រាវជ្រាវអំពីសរីរវិទ្យានិងអាជីវកម្ម

-ចំពោះប្រព័ន្ធចៀរជ័រពូជ S/$_2$ d4 7d/7 : ពូជ IRCA 230 ទទួលទិន្នផលខ្ពស់ជាងពូជ GT1 ពូជPB260 ពូជRRIM712 នៅថ្នាំ T1: ET 2.5% Pal (1) 8/$_y$ ។

### ៥.៥ ការស្រាវជ្រាវ ការដាំដុះ និងការពារ

-វាស់ទំហំដើមកៅស៊ូនៅពេលបើកមុខចៀរដំបូងចម្ការពិសោធន៍ IC-2007, Planting densities on clone PB260, IRCA230, Fertilizer test on clone PB217, T1&T2-2007

-សហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ Nagoya Kyushu and Hawaii។

### ៥.៦ ការងារនៅស្ថានីយអនុវត្ត

-លាបថ្នាំរំញោចនិងលាបខ្លាញ់គោ

-ដាំពូជ CMB បានចំនួន៣៨៥ដើម គឺពូជ FDR4575 ចំនួន២៥ដើម, CDC312 ចំនួន៨០ដើម, FDR5788 ចំនួន២០០ដើម, PMB1 ចំនួន៨០ដើម។

**៥.៧ ការងារក្នុងមន្ទីរពិសោធន៍យថាប្រភេទ**

-ធ្វើតេស្តវិភាគសំណាកយថាប្រភេទចំនួន១៥ភាគសំណាក ដើម្បីបញ្ជាក់គុណភាពការកែច្នៃរបស់រោងចក្រ និងសិក្សាទៅលើកៅស៊ូប្រភេទ TSRCV

-រៀបចំសំណាកមន្ទីរពិសោធន៍ធ្វើតេស្តមន្ទីរក្នុងស្រុកលើកទី៣៦ ដើម្បីវាយតម្លៃសមត្ថភាពមន្ទីរពិសោធន៍ និងការឈានទទួលស្គាល់ជាមន្ទីរពិសោធន៍មូលដ្ឋាន

-បន្តរៀបចំសៀវភៅណែនាំសម្រាប់ការសម្អាតទឹកសំណល់រោងចក្រកែច្នៃកៅស៊ូ។

## ៦ ផ្នែករដ្ឋបាល

-ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា *ក្នុងខែចំនួន៤៦០ច្បាប់* សរុបចំនួន៤.៨៧៩ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ *ក្នុងខែចំនួន៣៤៥ច្បាប់* សរុបចំនួន៣.៧៧៨ច្បាប់ និងទទួលពីរាជធានី ខេត្ត *ក្នុងខែចំនួន១០៣ច្បាប់* សរុបចំនួន១.០៧៤ច្បាប់

-បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត *ក្នុងខែចំនួន៥០៨ច្បាប់* សរុបចំនួន៧.៦៣០ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ *ក្នុងខែចំនួន២១ច្បាប់* សរុបចំនួន៤៦០ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ *ក្នុងខែចំនួន២៩ច្បាប់* សរុបចំនួន៧០៤ច្បាប់

-ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-បើកវគ្គបណ្តុះបណ្តាលស្តីពីអំពីប្រព័ន្ធវាយតម្លៃគំរូសម្រាប់ដំណាំស្រូវដែលមានអ្នកចូលរួមសរុប២៤នាក់

-បើកវគ្គបណ្តុះបណ្តាលគ្រូជំនាញអំពីបង្ហុបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពដំណាំស្រូវដែលមានអ្នកចូលរួម២៥នាក់

-បើកវគ្គបណ្តុះបណ្តាលដល់កសិករនិងទិវាស្រែបង្ហាញដែលមានអ្នកចូលរួមចំនួន៣០នាក់ នៅខេត្តកោះកុង

-ចូលរួមជាវាគ្មិននៅក្នុងវេទិកាស្រូវអង្ករកម្ពុជា ក្រោមប្រធានបទស្តីពីការស្រាវជ្រាវអង្ករសម្រាប់ជំនួញអង្ករ

-ចុះពិនិត្យមើលស្ថានភាពទូទៅលើការដាំដុះដំណាំស្រូវនៅខេត្តបាត់ដំបង សៀមរាប ព្រៃវែង និងខេត្តកំពង់ស្ពឺ

-ចុះប្រមូលព័ត៌មានអំពីជីវភាពរស់នៅរបស់ប្រជាជនដែលពាក់ព័ន្ធនឹងការប្រកបរបរនេសាទត្រីនៅខេត្តតាកែវ ខេត្តព្រៃវែង និងខេត្តស្វាយរៀង

-រៀបចំទិវាស្រែបង្ហាញបង្ហុបច្ចេកទេសបង្កើនផលិតភាពដំណាំស្រូវដែលមានអ្នកចូលរួមចំនួន៤៦នាក់ នៅខេត្តមណ្ឌលគិរីនិងខេត្តស្ទឹងត្រែង

-ចុះកំណត់សមាសភាពចង្រៃលើសណ្តែកសៀងនិងប្រមូលសំណាកជំងឺមួយចំនួនលើដំណាំស្រូវនៅខេត្តកំពង់ចាម

-ចុះយកសំណាកនិងប្រមូលទិន្នន័យពិសោធន៍នៅខេត្តពោធិ៍សាត់និងខេត្តបាត់ដំបង

-បន្តបញ្ចូលទិន្នន័យនិងសរសេររបាយការណ៍ស្រាវជ្រាវប្រចាំឆ្នាំ២០១៣។

## ៨ សាលាជាតិកសិកម្មព្រែកលៀប

### ៨.១ និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបមានចំនួន១.៥៦២នាក់(ស្រី ៥០២នាក់)ក្នុងនោះ÷

• និស្សិតអាហារូបករណ៍(ទូទៅ)ចំនួន១.០៥០នាក់ ក្នុងនោះស្រី៣៩៣នាក់ ÷

-ថ្នាក់បរិញ្ញា *៨១៣*នាក់ (ស្រី ៣០៥នាក់ )សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី

-ថ្នាក់បរិញ្ញារង *២៣៧*នាក់ (ស្រី ៨៨នាក់) សិក្សាលើមុខជំនាញក្សេត្រសាស្ត្រ រុក្ខកម្ម ផលិតកម្មនិងបសុព្យាបាល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម ជលផល កសិឧស្សាហកម្ម និងសុរិយោដី។

• និស្សិតអាហារូបករណ៍(ព្រឹទ្ធសភា)ចំនួន០៣នាក់ ក្នុងនោះស្រី០១នាក់ ÷

-ថ្នាក់បរិញ្ញា *០៣*នាក់ (ស្រី០១នាក់) សិក្សាលើវិទ្យាសាស្ត្រកសិកម្ម និងវិទ្យាសាស្ត្រនិងវិជ្ជសាស្ត្រសត្វ។

• និស្សិតអាហារូបករណ៍(សម្តេច ហ៊ុន សែន)ចំនួន៥៧នាក់ ក្នុងនោះស្រី២០នាក់ ÷

-ថ្នាក់បរិញ្ញា *៥៧*នាក់ (ស្រី ២០នាក់) សិក្សាលើវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិទ្យាសាស្ត្រនិងវិជ្ជសាស្ត្រសត្វ ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី។

• និស្សិតអាហារូបករណ៍ផ្សេងៗចំនួន៧៦នាក់ ក្នុងនោះស្រី២១នាក់ ÷

-ថ្នាក់បរិញ្ញា *៧១*នាក់ (ស្រី ១៨នាក់) សិក្សាលើវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិទ្យាសាស្ត្រនិងវិជ្ជសាស្ត្រសត្វ ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី

-ថ្នាក់បរិញ្ញារង *០៥*នាក់ (ស្រី ០៣នាក់) សិក្សាលើជំនាញក្សេត្រសាស្ត្រ ជំនាញកសិឧស្សាហកម្ម ជំនាញកៅស៊ូ។

• និស្សិតអាហារូបករណ៍(សាលាជាតិកសិកម្មព្រែកលៀប)ចំនួន១៩នាក់ ក្នុងនោះស្រី០៣នាក់ ÷

-ថ្នាក់បរិញ្ញា *១៨*នាក់ (ស្រី ០៣នាក់) សិក្សាលើវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវិជ្ជសាស្ត្រសត្វ ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម និងសុរិយោដី

-ថ្នាក់បរិញ្ញារង *០១*នាក់ (ស្រី ០នាក់) សិក្សាលើជំនាញផលិតកម្មនិងបសុព្យាបាល។

• និស្សិតបង់ថ្លៃចំនួន១៩៦នាក់ ក្នុងនោះស្រី២៧នាក់ ÷

-ថ្នាក់បរិញ្ញា *១៥៤*នាក់ (ស្រី ២៤នាក់ )សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី

-ថ្នាក់បរិញ្ញារង*៤២*នាក់ (ស្រី ០៣នាក់) សិក្សាលើមុខជំនាញក្សេត្រសាស្ត្រ រុក្ខកម្ម ផលិតកម្មនិងបសុព្យាបាល និងផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ។

• និស្សិតបណ្តុះបណ្តាលបន្តថ្ងៃសៅរ៍-អាទិត្យចំនួន១៦១នាក់ ក្នុងនោះ ស្រី៣៧នាក់ ÷

-ថ្នាក់បរិញ្ញា *១៤២*នាក់ (ស្រី ៣៦នាក់) សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ និងសុរិយោដី

-ថ្នាក់បរិញ្ញារង *១៩*នាក់ (ស្រី ០១នាក់) សិក្សាលើមុខជំនាញផលិតកម្មនិងបសុព្យាបាល ។

### ៨.២ ការងារផលិតកម្មនិងស្រាវជ្រាវ

-កសិដ្ឋានដំណាំលម្អបានដាំផ្កា ឈើពណ៌ ដូងតាំង និងពង្រីកពូជបន្ថែមសម្រាប់ការអនុវត្តនិងដាំលម្អក្នុងបរិវេណសាលាជាតិ បណ្តុះកូនក្ងាន ស្លាកន្ទុយកំប្រុក។

## ៩ សាលាជាតិកសិកម្មកំពង់ចាម

### ៩.១ និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១២-២០១៣ សរុបមានចំនួន១.៥៥៩នាក់(ស្រី ៦០៨នាក់)ក្នុងនោះ ÷

-និស្សិតអាហារូបករណ៍សរុប១.២៩៥នាក់(ស្រី៥៣៥នាក់)ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់(ស្រី ៣៣៩នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម៣៨២នាក់(ស្រី១៩៦នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

-និស្សិតសិក្សាបង់ថ្លៃ២៦៤នាក់ (ស្រី៧៣នាក់) ថ្នាក់បរិញ្ញាចំនួន២៥២នាក់(ស្រី៧៣នាក់) និងថ្នាក់បរិញ្ញារងចំនួន ១២នាក់(ស្រី០នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ ។

### ៩.២ ការងារពិសោធន៍ស្រាវជ្រាវ

-ធ្វើការពិសោធន៍ដំណាំសណ្តែកសៀង

-ធ្វើការពិសោធន៍លើប្រសិទ្ធភាពជីអាសូត ផូស្វរ ប៉ូតាស្យូម លើការលូតលាស់ដំណាំម្ទេសដៃនាង

-ពិសោធន៍តាមដានការលូតលាស់ជ្រូកមេក្នុងការចិញ្ចឹមតាមរយៈការប្រើប្រាស់ចំណីឧស្សាហកម្ម។

### ៩.៣ ការងារស្រាវជ្រាវ ផ្សព្វផ្សាយ និងការផ្ទេរបច្ចេកវិទ្យាកសិកម្ម

-លើកគម្រោងចំនួន១១ស្នើសុំថវិកាសម្រាប់ធ្វើការស្រាវជ្រាវលើប្រធានបទស្តីពីការពិសោធន៍កសិកម្ម វារីវប្បកម្ម បសុវប្បកម្ម និងសង្គមជនបទ

-បន្តការងារស្រាវជ្រាវផលិតកម្មដំណាំស្រូវ ដែលបានឧបត្ថម្ភជំនួយពី ACIAR-CARF

-បន្តការងារស្រាវជ្រាវលើបសុវប្បកម្ម ដែលបានឧបត្ថម្ភជំនួយពី DEL-phe(UK)

-ផ្សព្វផ្សាយពីការធ្វើតណាទានស្រូវពូជ ជ្រូកពូជ និងចាក់វ៉ាក់សាំងការពារជំងឺសត្វគោ-ក្របី នៅតាមមូលដ្ឋានឃុំ-ស្រុក ក្នុងខេត្តកំពង់ចាម

-ផ្តល់ជ្រូកពូជជូនដល់កសិករក្រីក្រនៅស្រុកត្រាំកក់ខេត្តតាកែវនិងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមបានចំនួន១៨គ្រួសារ

-ធ្វើការប្រជុំកសិករណែនាំពីការប្រើប្រាស់ថ្នាំពុលគីមី ជីគីមី និងជីសរីរាង្គ នៅក្នុងមូលដ្ឋានស្រុកត្រាំកក់ ខេត្តតាកែវ និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

## ១០ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

-និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៥.៦៩៧នាក់ (ស្រី១.២៣៣នាក់) ចែកចេញជា០៩មហាវិទ្យាល័យគឺ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រកៅស៊ូ ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន២៥លើក និងក្រៅប្រទេសចំនួន២១លើក និងសិក្ខាសាលាក្នុងប្រទេសចំនួន២៤លើក និងក្រៅប្រទេសចំនួន២២លើក

-បញ្ជូននិស្សិតទៅចូលរួមវគ្គបណ្តុះបណ្តាលនិងកម្មសិក្សានៅក្រៅប្រទេសចំនួន១២នាក់ និងមន្ត្រីរាជការចំនួន ១២នាក់

-បញ្ជូននិស្សិតទៅធ្វើកម្មសិក្សានៅប្រទេសអ៊ីស្រាអែលចំនួន៣០នាក់

-អនុវត្តគម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ចំនួន២៣គម្រោង គម្រោងទាំងនោះមានគម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ចម្រុះជំនាញផ្នែកវិទ្យាសាស្ត្រកសិកម្ម ផ្នែកវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ ផ្នែកវិទ្យាសាស្ត្រព្រៃឈើ ផ្នែកវិទ្យាសាស្ត្រជលផល ផ្នែកស្រាវជ្រាវ-ផ្សព្វផ្សាយ ផ្នែករៀបចំដែនដីនិងរដ្ឋបាលដីធ្លី

-ធ្វើការផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមករវាងសាស្ត្រាចារ្យនិងនិស្សិត ព្រមទាំងខិតខំពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិយ៉ាងទូលំទូលាយ ក្នុងទិសដៅពង្រឹងគុណភាពអប់រំឱ្យបានល្អប្រសើរដើម្បីឱ្យមានលក្ខណៈប្រកួតប្រជែង

-បញ្ជូននិស្សិតចុះជួយវាស់វែងដីធ្លីជូនប្រជាជន ដើម្បីចូលរួមអនុវត្តនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លីរបស់រាជរដ្ឋាភិបាលចំនួន៤២៩នាក់ មកពីមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រកសិកម្ម និងសេដ្ឋកិច្ចកសិកម្មនិងជនបទ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួមការងារបង្កបង្កើនផលស្រូវវស្សាឆ្នាំ២០១៣នេះ ប្រជាកសិករបាននឹងកំពុងខិតខំជំរុញការងារប្រមូលផលស្រូវរដូវវស្សានិងស្តារផ្ទៃដីខូចខាតដែលទទួលរងនូវគ្រោះធម្មជាតិនិងការដាំដុះដំណាំនារដូវប្រាំងជាបន្តទៀត។ ជាមួយនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការខិតខំថែទាំដំណាំស្រូវក៏ដូចជាការថែទាំដំណាំផ្សេងៗនិងយកចិត្តទុកដាក់លើការគ្រប់គ្រងនិងប្រើប្រាស់ទឹកឱ្យមានប្រសិទ្ធភាព ព្រមទាំងរក្សាទឹកទុកឱ្យបានគត់មត់នៅចុងរដូវ។

IV- **និសន្ទេ**

-ជំរុញតាមដានសភាពការណ៍វាំងស្ងួតនៅចុងរដូវ

-ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០១ និង ០២

-បន្តជំរុញកំណត់ព្រំប្រទល់ដែនព្រៃឈើ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីគ្រប់ភាគីពាក់ព័ន្ធ ហើយត្រូវសម្រេចឱ្យបានប្រវែង ១.០០០គីឡូម៉ែត្រ

-ជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

-បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី ដោយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ និងការពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីចំនួន ១០០កន្លែងបន្ថែមទៀត

-បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ

-បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការអប់រំផ្សព្វផ្សាយពីសារប្រយោជន៍ស្តីពីព្រៃឈើ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេស

-បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពស្រាវជ្រាវ

-កំណត់តំបន់ព្រៃឈើរេចរិលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

-បន្តចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះដេញថ្លៃផល អនុផលព្រៃឈើដែលរឹបអូសដោយសាលក្រម ដីកាសម្រេច ពិន័យអន្តរការណ៍ និងឈើអញ្ញាតជន(ឈើគ្មានម្ចាស់)នៅទូទាំងប្រទេស

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់

-រៀបចំសេចក្តីណែនាំនិងដាក់ឱ្យប្រើប្រាស់សៀវភៅកត់ត្រាឈើចេញចូលតាមរោងសន្និធិផល អនុផលព្រៃឈើ

-បន្តត្រួតពិនិត្យបទល្មើសនេសាទទឹកសាបនៅរាជធានី ខេត្ត ជាពិសេសតំបន់អភិរក្សឱ្យកាន់តែមានប្រសិទ្ធភាព

-បន្តការតាមដានសកម្មភាពអាជីវកម្មនេសាទសមុទ្រ

-បន្តការងារផ្សព្វផ្សាយការអភិវឌ្ឍវិស័យវារីវប្បកម្មនិងការគ្រប់គ្រងធនធានជលផល

-បន្តការងារស្រាវជ្រាវដើម្បីកំណត់អត្តសញ្ញាណកូនត្រីទៅតាមប្រភេទនីមួយៗនៅតាមដងទន្លេមេគង្គ

-រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

-ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សីនិងជំងឺផ្តាសាយ (A) H1N1

-ពង្រឹងទប់ស្កាត់ចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

-ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

-ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

-ចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍លើកទី ១០៥ ជាមួយ IRA

-អង្កេតទូទៅស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូនិងត្រួតពិនិត្យជំងឺកៅស៊ូ

-ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

-ពង្រឹងការងារបញ្ជីកាគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី ខេត្ត

-បន្តចុះពិនិត្យផ្ទាល់ដល់ទីតាំងរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់

-បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងគោលការណ៍លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំអំពីការងារគ្រប់គ្រងមន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រងធនធានមនុស្សឱ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកម្រិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង

-ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឱ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា

-ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិក្នុងវិស័យកសិកម្មឱ្យបានទូលំទូលាយជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

-បន្តរៀបចំច្បាប់លិខិតបទដ្ឋានគតិយុត្ត និងអត្ថបទក្រោមច្បាប់តាមអនុវិស័យ ដើម្បីដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឱ្យបានសមស្រប៕

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ [illegible] ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

បណ្ឌិត អ៊ុក រ៉ាប៊ុន